# ជំណាំត្រកួន



## I. ស្ថានភាពទូទៅ

យោងតាមប្រភពឯកសារបុរេប្រវត្តិមកពីតំបន់អេស៊ីព និង អារ៉ាប់ក្នុងឆ្នាំ ១៧៧៥ បានអោយដឹងថា ក្រុមអ្នកវិទ្យាសាស្ត្រជំនាន់នោះបានធ្វើការរុករកប្រមូល ព្រមទាំងអភិរក្សពូជត្រកួនមានច្រើនកន្លែង និងមកពីទ្វីប ផ្សេងៗ ដូចជាតំបន់ដី



សើមដែលមានអាកាសធាតុក្តៅនៃទ្វីបអាស៊ីប្រហាក់ប្រហែលនឹងប្រទេសឥណ្ឌាភូមិភាគខ្លះនៃអាស៊ីអាគ្នេយ៍តំបន់ ខ្លះទ្វីបអាហ្វ្រិក ព្រមទាំងភូមិភាគខាងត្បូងនិងកណ្តាលនៃទ្វីបអាមេរិក ។ ដោយឡែកនៅតំបន់នោះគេមិនបានឃើញមានការ និយមចូលចិត្តដាំដុះ និង ប្រើប្រាស់ផលិតផលនេះទេ ផ្ទុយទៅវិញ វាជាដំណាំដ៏មានប្រជាប្រិយភាពនៅ ភូមិភាគអាស៊ីអាគ្នេយ៍ ដូចជា នៅប្រទេសចិន Hong Kong Taiwan Ning Southem China ក្រោយមកនៅចុង សតវត្សទី ១៥ វាបានរីកពេញទូទាំងទ្វីបអាស៊ី ។ វាត្រូវបានរាប់បញ្ចូលទៅក្នុងគ្រួសារ Convolbulacea លំដាប់ Ipomoea ឈ្មោះវិទ្យាសាស្ត្រហៅថា Ipomoea aquatica ឈ្មោះធម្មតាអាចហៅ បានច្រើនយ៉ាង Kang Kong Water convolvulus Water spinach តែការនិយម





តារាងអាហារូបត្ថម្ភក្នុងទំងន់ ១០០ ក្រាម បរិភោគបាន

| ផ្នែកប្រើប្រាស់ | ថាមពល | ទឹក | ប្រូតេអ៊ីន | ប្រេង | កាបូស៊ី | សរសៃ | ផេះ | Ca | Mg | Fe | VA | VC |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ខ្នាត | កាឡូរី | g | g | g | g | g | g | mg | mg | mg | mg | mg |
| ដើម - ស្លឹក | ១៣៤ | ៩០.០ | ៣.០ | ០.៣ | ៥.០ | ១.០ | ១.៦ | ៩១ | ៥២ | ៣.៣ | ៤០០០ | ១៣០ |

ឈ្មោះដំណាំបន្លែយកស្លឹក ។ យោងតាមការវិភាគរបស់អង្គការ FAO ឆ្នាំ ១៩៧២ អោយដឹងថាវាបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនសំរាប់ទ្រទ្រង់សរីរាង្គការដូចក្នុងតារាងខាងក្រោម ។





ប្រើជាងគេគឺ Kang Kong .... ។ តាមការបែងចែករបស់លោក Poiret ក្នុងឆ្នាំ ១៨១៤ ដោយសំអាងទៅលើពណ៌របស់ផ្កាមានពីរយ៉ាងគឺៈ

- ប្រភេទទី១ ពណ៌របស់ផ្កាស្វាយស្រាល ដើមពណ៌បៃតងចាស់ ឫពណ៌ឈាមជ្រូក ស្លឹកតូចល្មិត ហៅថា Red Kang Kong ឫត្រកួនព្រៃ ។
- ប្រភេទទី២ ពណ៌របស់ផ្កាស ដើមពណ៌បៃតងខ្ចី ថ្លោស ស្លឹកធំវែង ហៅថា White Kang Kong គេហៅថា ត្រកួនស ឫត្រកួនចិនព្រោះពូជនេះឱ្យយកទៅបង្កាត់ និងផលិតជាត្រកួនគោកដាំដោយគ្រាប់ផ្ទាល់ ។ ដោយសារធាតុចិញ្ចឹម រស់ជាតិ ក្លិន និង ងាយប្រើប្រាស់គ្រប់ពេល វាត្រូវបាននិយមចូលចិត្តច្រើនឡើងៗ ដែលគេអោយ ។

## បច្ចេកទេសដាំដុះ

ត្រកួនជាប្រភេទដំណាំមួយងាយស្រួលដាំជាងដំណាំឯទៀត ហើយដុះលូត លាស់មិនប្រកាន់រដូវ វាធន់ទ្រាំ ទៅនឹងអាកាសធាតុក្តៅ ប៉ុន្តែមិនធន់ទ្រាំទៅនឹងភាពរាំងស្ងួតឡើយ ។ ម្យ៉ាងទៀត វាក៏ជាដំណាំស្ថិតនៅក្នុងភាពធន់ ទ្រាំកំរិតជីអាស៊ីត និងបាស (ជូរ ប្រៃ)។ ប៉ុន្តែដើម្បីអោយទទួលបានលទ្ធផលល្អគេត្រូវអនុវត្តន៍នូវវិធី សាស្ត្រជាច្រើន ដូចតទៅ:





### ១- ការជ្រើសរើសពូជ

ការជ្រើសរើសពូជសំរាប់ធ្វើការដាំដុះ វាអាស្រ័យទៅតាមវិធីសាស្ត្រនៃការ ដាំ ព្រោះត្រកួនគេដាំបាន២ របៀបគឺ របៀបត្រកួនគោក គេដាំដោយគ្រាប់ពូជ ប៉ុន្តែចំពោះត្រកួនស្រែ គេដាំដោយកំណាត់ទងហៅថា ស្ទូង ។

- ការជ្រើសរើសគ្រាប់សំរាប់ដាំថ្នាលគោក មានពូជជាច្រើនដែលធ្លាប់បានដាំដុះនៅប្រទេសកម្ពុជាយើង ក្នុងនោះនាំមកប្រទេសថៃ និងវៀតណាម ប៉ុន្តែពូជមកពីថៃ ដើមធំថ្លោស ពណ៌បៃតងខ្ចីរលោង ស្លឹកធំខ្ចី មាន២ពូជ គឺឈ្មោះ Loet phan និង Bai



- ការជ្រើសរើសទងសំរាប់ធ្វើពូជៈ ត្រូវកាត់ទងត្រកួនដែលថ្នាំងរបស់វាមាន ដុះចេញឫសច្រើនមាន ប្រវែង ២៥-៣០ សម មានពាថ្នាំងជាមធ្យមយកមករក្សាទុករយៈពេល ២-៣ថ្ងៃដើម្បីអោយការដុះ ឫសចេញបានកាន់តែច្រើនហើយយកទៅស្ទូងលូតលាស់លឿន។ ក្នុង១ហ.ត គេប្រើទំងន់គ្រាប់ពូជជាមធ្យម ៨០-១០០ គក្រ តែចំពោះការដាំដោយកំណាត់ទងជាមធ្យម ២០០.០០០ កំណាត់ ។

## ២-ការជ្រើសរើស និង រៀបចំដី

ត្រកួនដុះលូតលាស់បានលើដីគ្រប់ប្រភេទ ប៉ុន្តែវាត្រូវការទឹកច្រើន ជាងដំណាំឯទៀតដូចនេះ ដីសំរាប់ដាំដុះ ត្រកួនត្រូវមានប្រភពទឹកនៅក្បែរ ឫដីសើមជាប្រចាំ





Phai រីឯពូជមកពីប្រទេសវៀតណាមឈ្មោះ Green Kang Kong ដើមតូចស្លឹក ល្អិត ពណ៌បៃតងចាស់មានបន្ទាបន្តិច១។ គ្រាប់ពូជត្រកួនភាគច្រើនមិនត្រូវរងការបំផ្លាញដោយសត្វល្អិតឡើយ ប៉ុន្តែ ការទុកដាក់មិនបានត្រឹមត្រូវនៅក្នុងឃ្លាំងធ្វើអោយដំណុះមានភាគរយទាបត្រូវជ្រើសរើសយកពូជ ដែលមាន ដំណុះពី ៨៥%ឡើងទៅសំរាប់ ធ្វើការដាំដុះ។



សំរាប់ត្រកួនស្រែ ។

- ការរៀបចំដីសំរាប់ដាំគ្រាប់ៈ ត្រូវភ្ជួរ និងរាស់បំបែកដីព្រមទាំងប្រមូលយកស្មៅចេញអោយបានច្រើនសារ បន្ទាប់មកលើករងអោយមានកំពស់ ២០-២៥ សម ទទឹងរង ១០០-១២០ សម ដោយយកជីធម្មជាតិលាមកសត្វគ្រប់ប្រភេទបាចពីលើរងអោយបានច្រើន ១-២ បង្គីសំរាប់ថ្នាល ១០ម២ ហើយយកជី ១៥.១៥.១៥ ចំនួន ១០០-១៥០ ក្រាមដាក់បន្ថែមហើយរាស់លប់នៅក្នុងដី ។

- ការរៀបចំដីសំរាប់ត្រកួនទឹកៈ ដែលហៅថា ត្រកួនស្រែត្រូវភ្ជួររាស់ដីស្រែមានទឹកសើមៗ មានភ្លឺពទ្ធ័ជុំ វិញ។ មុននឹងរាស់ត្រូវយកជីធម្មជាតិ និង ជី ១៥.១៥.១៥





ទៅបាចជាមុន បន្ទាប់មកភ្ជួរលប់នៅក្នុងដី ហើយរាស់បំបែកដីអោយល្អិតប្រមូលយកស្មៅចេញអោយស្អាត ។

### ៣-ការដាំដុះ

- ការបំបែកដោយគ្រាប់ៈ ដំបូងត្រូវឆ្វូតជាចង្អូរៗ ទទឹងរងដោយប្រើចន្លោះចង្អូរ ១៥សម ជំរៅ ៣-៤ សម បន្ទាប់មកយកគ្រាប់ពូជទៅរោយតាមចង្អូរនោះចំងាយពីគ្រាប់មួយទៅមួយ ១-២សម រួចលប់ដីពីលើបន្តិចៗ និងបាចកំណាត់ចំបើង ខ្ចីៗ ពីលើអោយជិតស្រោចទឹកអោយជោគរាល់ថ្ងៃ មួយថ្ងៃ២ដង រយៈពេល ៤-៥ថ្ងៃ ត្រកួន នឹងដុះចេញផុតពីដី ។



- ការដាំដោយកំណាត់ទងៈ គឺត្រូវយកទងត្រកួនដែលបានរក្សាទុក ២-៣ថ្ងៃ រួចយកមកទៅស្ទូងក្នុងស្រែ ដីសើម ដោយប្រើចន្លោះជួរ ៤0សម ចន្លោះគុម្ព ៣0សម មួយគុម្ពមួយទង របៀបស្ទូងត្រូវកប់ថ្នាំងមួយចូលទៅក្នុងដីក្រោយពីស្ទូងបាន ៥-៧ ថ្ងៃ ត្រូវបញ្ចូលទឹកអោយលិចរយៈពេល១យប់ បន្ទាប់មកបញ្ចេញទឹកចោលមួយភាគទុកមួយភាគ ត្រាំគល់ត្រកួនធ្វើរបៀបនេះត្រកូនដុះលូតលាស់លឿនចាប់បានប្រមូលផល។





## ៤-ការជ្រុំជ្រោយដី និង ដកស្មៅ

ការដាំដុះដោយគ្រាប់ពូជ គេត្រូវជ្រុំជ្រោយដី និងដកស្មៅក្រោយពីដាំបាន រយៈពេល ១0ថ្ងៃ គឺដកយកស្មៅចេញហើយជ្រុំដីអោយផុសពេលលើករង ព្រមទាំង លប់គល់បន្តិចៗ ធ្វើរបៀបនេះត្រកួនមានលទ្ធភាពដុះលូត លាស់កាន់តែលឿន ។

ការដាំដុះដោយកំណាត់ទងៈ មិនត្រូវជ្រុំជ្រោយដីឡើយ ប៉ុន្តែគេត្រូវព្យាយាម ដកស្មៅចេញពីស្រែត្រកួន រយៈពេល ១0-១៥ថ្ងៃ ក្រោយពីស្ទូង ហើយបន្តការដក រហូតដល់ត្រកួនដុះលូតលាស់ជិតដីគ្របពីលើស្មៅ ។





cercospora Sp ជាពិ សេសធ្វើអោយកូនត្រកួនរលួយក្រោយពីដុះបានរយៈពេល ៥១០ថ្ងៃ ក្រោយដាំ ។

- ជំងឺពកដើម ឫស ហៅថា Root knot nematodes បណ្តាលមកពីមេរោគរស់នៅក្នុងដីឈ្មោះ Meloidogyne Spp ធ្វើអោយត្រកួនពកដើម ហើយឫសពកជា កង់ៗច្រើនជួបខ្លាំងជាងគេព្រមទាំងបាត់បង់ ទិន្នផលមួយចំនួន ។ដើម្បីការពារជំងឺទាំងនេះត្រូវដាំដោយប្តូរដី សំអាតស្មៅអោយស្អាត ដាំឱ្យមានចន្លោះជួរ គុម្ពត្រឹម ត្រូវហើយឆាប់ប្រមូលផលជាពិសេសគេអាចយកគ្រាប់ពូជទៅលាយជាមួយថ្នាំ សំលាប់ផ្សិតមុន នឹងធ្វើការដាំដុះ ។

## ២- អំពីសត្វល្អិតស៊ីបំផ្លាញ

គេសង្កេតឃើញមានសត្វល្អិតសំខាន់ៗចំនួន ៣ប្រភេទ តែងស៊ីនិងជញ្ជក់ស្លឹក ដើម ធ្វើអោយបាត់បង់ទិន្ន ផលមួយចំនួនដូចជា:

- ដង្កូវហ្វូងឈ្មោះ Grass Cutworm Spodoptera litura វាកាត់ស្លឹកដើម ហើយមានលក្ខណៈ ជាហ្វូង ឆ្លងពីស្រែមួយទៅមួយធ្វើឱ្យបាត់បង់ទិន្នផលមួយភាគធំ ។

- ដង្កូវកន្ទុយវែង Tiger moth caterpillar Diderisia metarhoda ដង្កូវប្រភេទនេះស៊ីស្លឹក និងត្រួយ ខ្ចីៗលក្ខណៈផ្តុំដោយកន្លែងៗ ហើយបន្សល់ទុកទ្រនង់ ស្លឹក វាមានមាឌធំៗបណ៌បៃតងវែង មានកន្ទុយស្រួចវែងបាស់ ឡើងលើធ្វើអោយ ប៉ះពាល់ដល់សោភណ្ឌភាពបន្លែ (ដាច់ ឫរហែកស្លឹក) ។

- ចៃបៃតង Green peach aphid i Mycus persicae វារោមជញ្ជក់ស្លឹក



## ៥- ការស្រោចទឹក និងផ្តល់ជី

ត្រកួនជាប្រភេទបន្លែយកស្លឹក (Young Shoot) ដូចនេះការលូតលាស់លឿន ឬយឺតវាអាស្រ័យទៅនឹង កំរិតនៃការផ្តល់ទឹកព្រមទាំងសារធាតុអាសូត (N) ។ ដើម្បីអោយការលូតលាស់ទាន់ពេលវេលាគេត្រូវស្រោចទឹក អោយដីសើមជានិច្ច សំរាប់ត្រកួនគោកហើយមួយសប្តាហ៍គេត្រូវយកជីអ៊ុយរ៉េទៅលាយទឹកស្រោចម្តង ឬទឹកត្រាំ ក្នុងកំរិត១,២០ ។ ដូចគ្នានេះ ចំពោះកូនស្រែ ត្រូវបញ្ចូលទឹកអោយទៀតទាត់ មិនត្រូវអោយដីស្ងួត កាលណាដីស្ងួតធ្វើអោយទងត្រកួនរឹង ហើយរយៈពេល ៧-១០ថ្ងៃ គេត្រូវដាក់បន្ថែមជីអាសូតម្តង ១ហត ៥០-៧០គក្រ ពេលស្រែត្រកួន មានទឹកសើមៗ ។

## III. អំពីជំងឺសត្វល្អិតបំផ្លាញ

ដំណាំប្រភេទនេះ ពុំមានការគ្រោះថ្នាក់ធ្ងន់ធ្ងរពីជំងឺ និងសត្វល្អិតឡើយ ប៉ុន្តែ វាក៏នៅតែមានកត្តាបំផ្លាញ ខ្លះៗដែរដូចជា:

### ១-អំពីជំងឺ

ជំងឺដែលមានកើតនៅលើត្រកួនជាញឹកញាប់មានដូចជា:

- ជំងឺពពាលស្លឹក White rust spot បណ្តាលមកពីមេរោគឈ្មោះ Albugo ចានដិដា ធ្វើអោយលឿងស្លឹក ហើយស្ងួតជ្រុះស្លឹកជាជំងឺផ្សិត ។

- ជំងឺរលួយកូន Damping off បណ្តាលមកពីមេរោគឈ្មោះ Pythium Sp,

ដើមត្រកួនធ្វើអោយដើម ស្លឹករួញលែងលូតលាស់ ព្រមទាំងបង្កអោយកើតវីរុសផ្សេងៗ ជាច្រើនប្រភេទ ។ ដើម្បីកាត់បន្ថយនូវសត្វចង្រៃទាំងនេះ គេត្រូវមានវិធានការជា ច្រើនរួមគ្នា ដូចជា ការរៀបចំដី ប្តូរមុខ ដំណាំ ជ្រើសរើសពូជ ជ្រើសរើសរដូវ ការកំចាត់ ស្មៅជាដើម ព្រមទាំងគ្រប់គ្រងវត្ថុមានសត្វល្អិតមុនពេលវាលេច ចេញនូវប្រជាករ គ្រោះថ្នាក់រួមផ្សំនិង វិធានការគិមី ។

## IV. ការប្រមូលផល







គេអាចប្រមូលផលត្រកួនក្រោយពីដាំបានរយៈពេល២៨-៣៥ថ្ងៃ ។របៀបប្រមូលផលគេធ្វើឡើង ផ្សេង ៗ ពីគ្នាទៅតាមតំរូវការទីផ្សារ ដូចជា:



- ត្រកួនគោក: គេដកយកទាំងឫសក្រោយពីស្រោចទឹកអោយជ្រោករយៈពេល ៣០នាទី ប៉ុន្តែខ្លះទៀត គេ ច្រូតត្រកួនក្បែរដីយកតែដើមខ្ចីៗទៅប្រើប្រាស់ហើយទុកគល់នៅនឹងថ្នាលដដែលបន្ទាប់មកយក ជីអ៊ុយរ៉េទៅបាចពីលើបន្តិចៗស្រោចទឹកឱ្យជោគព្រឹកល្ងាចតែក្នុងរយៈពេល ៧-១០ថ្ងៃ គេអាចប្រមូលផលបានជាបន្តទៀតជាមធ្យមទិន្នផលប្រមូលបានពី ៨-១០ ត/ហ.ត
- ត្រកួនស្រែ: គេកាត់ទងត្រកួនរយៈពេល ៥-៧ថ្ងៃម្តងៗ អាចប្រមូលផល បានយ៉ាងច្រើនផង អាស្រ័យ ទៅនឹងការផ្តល់ជី និងទឹក ព្រមទាំងការកំចាត់ស្មៅផង ដែរ ។ ត្រកួនប្រភេទនេះទទួលបានទិន្នផលខ្ពស់ជាង ត្រកួន គោក ប៉ុន្តែចំពោះតំលៃ លើទីផ្សារវាមានកំរិតទាបជាងត្រកួនគោក ។